GOOD QUESTION GOOD ANSWER

**Written by Ven. S. Dhammika, translated by Ven.Votano Sophan Seng**

[1]

# What is Buddhism?

### *What is Buddhism?*

The name Buddhism comes from the word 'budhi' which means 'to wake up' and thus Buddhism is the philosophy of awakening. This philosophy has its origins in the experience of the man Siddhartha Gotama, known as the Buddha, who was himself awakened at the age of 35. Buddhism is now 2,547 years old and has about 500 million followers worldwide. Until a hundred years ago Buddhism was mainly an Asian philosophy but increasingly it is gaining adherents in Europe, Australia and America.

### *So Buddhism is just a philosophy?*

The word philosophy comes from two words 'philo' which means 'love' and 'sophia' which means 'wisdom'. So philosophy is the love of wisdom or love and wisdom, both meanings describe Buddhism perfectly. Buddhism teaches that we should try to develop our intellectual capacity to the fullest so that we can understand clearly. It also teaches us to develop love and kindness so that we can be like a true friend to all beings. So Buddhism is a philosophy but not just a philosophy. It is the supreme philosophy.

**សំនួរនិងចំលើយល្អៗ**

ដោយព្រះភិក្ខុធម្មិក :   *បកប្រែដោយភិក្ខុវោទានោ   សេង   សុភ័ណ*

# តើអ្វីគឺជាព្រះពុទ្ធសាសនា?

### *តើព្រះពុទ្ធសាសនាជាអ្វី?*

ព្រះសាសនាជាឈ្មោះដែលចេញពីពាក្យថា “ ពោធិ” ដែលមានន័យថា “ ត្រាស់ដឹង” ហើយព្រះពុទ្ធសាសនាជាទស្សនវិជ្ជានៃការត្រាស់ដឹង ។ ទស្សនវិជ្ជានេះមានប្រភពមកពីបទពិសោធន៍ពិតរបស់សិទ្ធត្ថគោត្តមដែលគេស្គាល់ថាជាព្រះពុទ្ធដែលព្រះអង្គត្រាស់ដឹងពេលព្រះជន្មាយុ៣៥ព្រះវស្សា ។ ព្រះពុទ្ធសាសនាឥឡូវនេះមានអាយុ២៥៤៧ឆ្នាំ ហើយមានសាសនិកជនជាង ៥០០លាននាក់ទូទាំងពិភពលោក ។ ១០០ឆ្នាំកន្លងផុតទៅព្រះពុទ្ធសាសនាបានជាទស្សនាវិជ្ជាសំខាន់របស់អាស៊ី ប៉ុន្តែបានកំពុងបង្កើនសាសនិកយ៉ាងច្រើននៅអ៊ឺរ៉ុប អូស្ត្រាលី និងអាមេរិកា ។

### *ដូច្នេះ   តើព្រះពុទ្ធសាសនាគ្រាន់តែជាទស្សនវិជ្ជាឬ?*

ពាក្យទស្សនវិជ្ជាមកពីពាក្យពីរម៉ាត់គឺហ្វីឡូមានន័យថាស្រលាញ់ និងសូហ្វៀមានន័យថាបញ្ញា ។ ដូច្នេះទស្សនវិជ្ជាគឺស្រលាញ់បញ្ញាឬស្រលាញ់និងបញ្ញា អត្ថន័យទាំងពីរបញ្ជាក់នូវភាពសុក្រឹតរបស់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាបង្រៀនយើងថា ចូរព្យាយាមអភិវឌ្ឍន៍កំរិតបញ្ញាអោយខ្ពស់បំផុតដើម្បីស្វែងយល់អោយច្បាស់លាស់ ។ហើយបង្រៀនផងដែរអោយយើងអភិវឌ្ឍន៍មេត្តធម៌និងករុណាធម៌ ដូច្នេះយើងអាចជាមិត្តពិតប្រាកដរវាងសត្វលោកទាំងអស់ ។ ដូច្នេះព្រះពុទ្ធសាសនាអាចជាទស្សនវិជ្ជា តែជាឧត្តមទស្សនវិជ្ជា ។

## *Who was the Buddha?*

In the year 624 B.C. a baby was born into a royal family in northern India. He grew up in wealth and luxury but eventually found that worldly comforts and security do not guarantee happiness. He was deeply moved by the suffering he saw all around and resolved to find the key to human happiness. When he was 29 he left his wife and child and set off to sit at the feet of the great religious teachers of the day to learn from them. They taught him much but none really knew the cause of human suffering and how it could be overcome. Eventually, after six years study and meditation he had an experience in which all ignorance fell away and he suddenly understood.

From that day onwards, he was called the Buddha, the Awakened One. He lived for another 45 years in which time he traveled all over the northern India teaching others what he had discovered. His compassion and patience were legendary and he had thousands of followers. In his eightieth year, old and sick, but still happy and at peace, he finally passed away.

## *តើនរណាជាព្រះពុទ្ធ?*

ក្នុងឆ្នាំ៦២៤មុនគ្រិស្តសករាជ ព្រះរាជបុត្រមួយព្រះអង្គបានប្រសូត្រឡើងក្នុងរាជត្រកូលភាគខាងជើងប្រទេសឥណ្ឌា។ ព្រះអង្គធំធាត់នៅលើគំនរទ្រព្យនិងលោកីយសុខ តែជាចុងក្រោយព្រះអង្គឆ្វេងយល់ថាសុវត្ថិភាពនិងសុខមាលភាពផ្លូវលោកមិនអាចធានាដល់សេចក្តីសុខពិតប្រាកដឡើយ។ ព្រះអង្គត្រូវបានជំរុញអោយគិតយ៉ាងខ្លាំងនូវសេចក្តីទុក្ខដែលប្រទះជុំវិញខ្លួន ហើយគិតនឹងត្រួសត្រាយផ្លូវទៅរកសេចក្តីសុខពិតប្រាកដរបស់មនុស្សជាតិ។លុះព្រះជន្ម២៩ព្រះវស្សា ព្រះអង្គបានចេញចាកព្រះរាជមហេសីនិងបុត្រហើយតាំងទីសេនាសេនះចំពោះបាទាគ្រូបង្រៀនសាសនាល្បីៗនៅសម័យនោះដើម្បីរៀនសូត្រពីពួកគេ។ គ្រូទាំងអស់នោះបង្រៀនស្ទើរតែអស់នូវចំណេះវិជ្ជា ប៉ុន្តែព្រះអង្គមិនចេះវិជ្ជាណាមួយដែលជាហេតុនៃសេចក្តីទុក្ខហើយនិងវិធីដើម្បីយកជំនះលើសេចក្តីទុក្ខនោះឡើយ។ ជាចុងក្រោយ បន្ទាប់ពីចំណាយពេលរៀនសូត្រ៦ព្រះវស្សា មានតែសមាធិទេដែលព្រះអង្គបានពិសោធន៏ជាមាគ៌ាទំលាយនូវអវិជ្ជាហើយព្រះអង្គបានយល់ពីហេតុនៃសេចក្តីទុក្ខភ្លាមៗ។

ពីពេលនោះរហូតមក គេហៅព្រះអង្គថាព្រះពុទ្ធមានន័យថាអ្នកត្រាស់ដឹង។ ព្រះអង្គចំណាយពេល៤៥ឆ្នាំទៀតដែលព្រះអង្គបានត្រាច់ចរជុំវិញឥណ្ឌាខាងជើងដើម្បីបង្រៀនអ្នកដទៃនូវអ្វីដែលបានរកឃើញ។ខន្តិធម៌និងករុណាធម៌របស់ព្រះអង្គមានលក្ខណៈជាប្រវត្តិសាស្ត្រហើយព្រះអង្គមានសាវ័ករាប់ពាន់នាក់។ក្នុងព្រះព្រះជន្មាយុ៨០ព្រះវស្សាទោះជរានិងព្យាធិក៏ព្រះអង្គមានសេចក្តីសុខនិងសេចក្តីស្ងប់ រហូតព្រះអង្គបានបរិនិព្វាននៅទីបំផុត។

## *Was the Buddha a god?*

No, he was not. He did not claim that he was a god, the child of a god or even the messenger from a god. He was a man who perfected himself and taught that if we follow his example, we could perfect ourselves also.

## *If the Buddha is not a god, then why do people worship him?*

There are different types of worship. When someone worships a god, they praise him or her, making offerings and ask for favours, believing that the god will hear their praise, receive their offerings and answer their prayers. Buddhists do not indulge in this kind of worship. The other kind of worship is when we show respect to someone or something we admire. When a teacher walks into a room we stand up, when we meet a dignitary we bow and greet, when the national anthem is played we salute. These are all gestures of respect and worship and indicate our admiration for persons and things. This is the type of worship Buddhist practise. A statue of the Buddha with its hands rested gently in its lap and its compassionate smile reminds us to strive to develop peace and love within ourselves. The perfume of incense reminds us of the pervading influence of virtue,

## *តើព្រះពុទ្ធជាអាទិទេពឬ?*

ទេ, ព្រះពុទ្ធមិនមែនជាអាទិទេពទេ។ ព្រះអង្គមិនដែលអះអាងថាព្រះអង្គជាអាទិទេព ជាបុត្ររបស់អាទិទេព ឬជាអ្នកនាំសាររបស់អាទិទេព។ព្រះអង្គជាបុរសដែលធ្វើអោយបរិបូរដោយព្រះអង្គឯង ហើយបង្រៀនថាបើយើងដើរតាមគំរូព្រះអង្គ យើងអាចនឹងបរិបូរដោយខ្លួនយើងផ្ទាល់ផងដែរ។

## *បើព្រះពុទ្ធមិនមែនជាអាទិទេពទេ ចុះហេតុអ្វីប្រជាជនគោរពបូជាព្រះអង្គ?*

មានវិធីបូជាខុសគ្នាច្រើនយ៉ាង។ពេលអ្នកណាម្នាក់បូជាអាទិទេព ពួកគេកោតសរសើរទេវបុត្រនិងទេវតា សែនសំណែននិងប្រាថ្នាបួងសួង ជឿជាក់ថាអាទិទេពនឹងឮពាក្យសរសើរ ទទួលនូវសំណែននិងតបស្នងនូវពាក្យបួងសួងរបស់គេ។ ពុទ្ធសាសនិកជននឹងមិនទំយើឬផ្តេកផ្តួលទៅតាមការបូជាបែបនេះ។ ការបូជាម្យ៉ាងទៀតគឺពេលយើងសំដែងសេចក្តីគោរពចំពោះនរណាម្នាក់ឬវត្ថុអ្វីម្យ៉ាងដែលយើងលើកសរសើរ។ ពេលគ្រូដើរចូលថ្នាក់រៀនយើងក្រោកឈរឡើង ពេលយើងជួបឥស្សរជនណាម្នាក់យើងជំរាបសួរ ពេលភ្លេងជាតិកំពុងបន្លឺងយើងគំនាប់គោរព។ ទាំងអស់នេះគឺឥរិយាបទនៃការគោរពនិងបូជានិងចង្អុលប្រាប់នូវការកោតសរសើររបស់យើងសំរាប់មនុស្សនិងវត្ថុទាំងឡាយ។ នេះជាប្រភេទនៃការបូជាដែលពុទ្ធសាសនិកជនបដិបត្តិ។ ព្រះពុទ្ធបដិមាដែលមានព្រះហស្តដាក់យ៉ាងថ្នមនៅលើភ្លៅ និងស្នាមញញឹមប្រកបដោយករុណាធម៌រំលឹកយើងអោយព្យាយាមអភិវឌ្ឍសុខសន្តិភាពនិងសេចក្តីស្រលាញ់នៅក្នុងខ្លួនយើង។ ក្លិនក្រអូបរបស់ធូបរំលឹកយើងឱ្យជ្រួតជ្រាបនូវកំឡាំងនៃគុណធម៌,

the candles reminds us of light of knowledge and the flowers which soon fade and die, reminds us of impermanence. When we bow, we express our gratitude to the Buddha for what his teachings have given us. This is the nature of Buddhist worship.

### *But I have heard people say that Buddhists worship idols.*

Such statements only reflect the misunderstanding of the persons who make them. The dictionary defines an idol as "an image or statue worshipped as a god". As we have seen, Buddhist do not believe that the Buddha was a god, so how could they possibly believe that a piece of wood or metal is a god? All religions use symbols to express various concepts. In Taoism, the ying-yang is used to symbolise the harmony between opposites. In Sikhism, the sword is used to symbolise spiritual struggle. In Christianity, the fish is used to symbolise his sacrifice. And in Buddhism, the statue of the Buddha also reminds us of the human dimension in Buddhist teaching, the fact that Buddhism is man-centred, not god-centred, that we must look within not without to find perfection and understanding. So to say that Buddhist worship idols is not correct.

ភ្លើងទៀនរំលឹកយើងដល់ពន្លឺនៃចំណេះដឹង និងផ្កាដែលស្រស់មួយរំពេចក៏ស្វិតស្រពោនទៅ រំលឹកយើងនូវធម៌អនិច្ចំគឺមិនទៀង។ ពេលយើងសំពះ យើងសំដែងនូវការដឹងគុណចំពោះព្រះពុទ្ធ សំរាប់អ្វីដែលព្រះអង្គបានបង្រៀននូវសច្ចធម៌ពិតរបស់ព្រះអង្គ។ នេះគឺជាធម្មជាតិធម្មតានៃការគោរពបូជារបស់ពុទ្ធបរិស័ទ។

### *តែខ្ញុំបានឮគេនិយាយថាពុទ្ធសាសនិកជនគោរពបូជារូបសំណាក។*

ពាក្យនោលដូច្នោះជាការឆ្លុះបញ្ចាំងនូវការយល់ខុសរបស់មនុស្សដែលធ្វើដូច្នោះ។ វចនានុក្រមកំណត់និយមន័យពាក្យរូបសំណាកថា រូបគំនូរឬរូបបដិមារដែលគេគោរពបូជាដូចជាអាទិទេព។ដូចដែលយើងបានឃើញយ៉ាងច្បាស់ថាពុទ្ធសាសនិកជនមិនជឿថាព្រះពុទ្ធជាអាទិទេពដូច្នេះតើគេអាចជឿថា កំណាត់ឈើឬក៏ដុំដែកជាអាទិទេពទេ? ។សាសនាទាំងអស់ប្រើប្រាស់និមិត្តសញ្ញាជំនួសអោយគំនិតផ្សេងៗគ្នា។ សាសនាតៅ យិង-យ៉ាងប្រើជានិមិត្តសញ្ញាសហវិជ្ជមានរវាងវត្ថុពីរផ្ទុយគ្នា។ ក្នុងសាសនាសិក ដាវប្រើតំណាងអោយការតស៊ូខាងចិត្តវិញ្ញាណ។ ក្នុងសាសនាគ្រិស្តត្រីគឺប្រើតំណាងអោយការលះបង់របស់យេស៊ូ។ ហើយក្នុងព្រះពុទ្ធសាសនា ពុទ្ធបដិមារជាការរំលឹកផងដែរដល់អាណាចក្ររបស់មនុស្សក្នុងព្រះពុទ្ធវចនៈនូវសច្ចភាពពិតដែលថាព្រះពុទ្ធសាសនាគឺយកមនុស្សជាធំ មិនមែនយកអាទិទេពជាធំទេ អ្វីដែលយើងត្រូវតែសំឡឹងមើលខ្លួនឯងមិនមែនត្រឹមតែស្វែងរកសុក្រឹតភាពនិងការយល់ដឹង។ដូច្នេះដែលនិយាយថាពុទ្ធសាសនិកជនគោរពបូជារូបសំណាកជារឿងមិនត្រឹមត្រូវ។

### *If Buddhism is so good why are some Buddhist countries poor?*

If by poor you mean economically poor, then it is true that some Buddhist countries are poor. But if by poor you mean a poor quality of life, then perhaps some Buddhist countries are quite rich. America, for example, is an economically rich and powerful country but the crime rate is one of the highest in the world, millions of old people are neglected by their children and die of loneliness in old people's homes, domestic violence and child abuse are major problems. One in three marriages end in divorce, pornography is easily available. Rich in terms of money but perhaps poor in terms of the quality of life.

Now if you look at some traditional Buddhist countries you find a very different situation. Parents are honoured and respected by their children, the crime rates are relatively low, divorce and suicide are rare and traditional values like gentleness, generosity, hospitality to strangers, tolerance and respect for others are still strong. Economically backward, but perhaps a higher quality of life than a country like America.

### *បើព្រះពុទ្ធសាសនាល្អ ចុះហេតុអ្វីប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះក្រីក្រម្លេះ?*

ប្រសិនបើភាពក្រីក្រដែលអ្នកនិយាយជាផ្នែកសេដ្ឋកិច្ច វាជារឿងពិតដែលថាប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះក្រីក្រមែន។ តែបើភាពក្រីក្រដែលអ្នកនិយាយជាផ្នែកគុណភាពជីវិត ពេលនោះប្រហែលជាប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះពិតជាមាន។ ឧទាហរណ៍ សហរដ្ឋអាមេរិកជាប្រទេសដែលមានខ្លាំងផ្នែកសេដ្ឋកិច្ចហើយមានអំណាច តែកំរិតការប្រព្រឹត្តអាជ្ញាកម្មជាប្រទេសមួយដែលខ្ពស់ជាងគេបង្អស់ក្នុងពិភពលោក មនុស្សចាស់ជរារាប់លាននាក់ត្រូវបានកូនទាំងឡាយបំបរបង់ចោល ហើយស្លាប់យ៉ាងអណោចអធមឯកោម្នាក់ឯងក្នុងផ្ទះជនជរា ចំណែកអំពើហិង្សានិងការប្រព្រឹត្តបំពានលើក្មេងជាបញ្ហាធំបំផុត។ ចុងក្រោយនៃជីវិតអាពាហ៍ពិពាហ៍មួយក្នុងចំណោមបីគឺការលែងលះគ្នា ហើយងាយនឹងបង្ហាញរូបអាសគ្រាម។ មានក្នុងលក្ខណ្ឌលុយកាក់ តែប្រហែលជាក្រក្នុងលក្ខណ្ឌនៃគុណភាពជីវិត។

ឥឡូវនេះបើអ្នកក្រលេកមើលប្រទេសដែលប្រកាន់ខ្ជាប់នឹងព្រះពុទ្ធសាសនាខ្លះ អ្នកនឹងជួបប្រទះនូវស្ថានភាពខុសគ្នាយ៉ាងខ្លាំង។ ឪពុកម្តាយជាទេវបុគ្គលដែលបុត្រធីតាត្រូវគោរពកោតខ្លាច អាត្រាអាជ្ញាកម្មស្ទើរតែមានកំរិតទាប ការលែងលះប្តីប្រពន្ធនិងអត្តឃាដកម្រនឹងមាន ហើយតំលៃខាងប្រពៃណីទំនៀមទំលាប់ដូចជាភាពទន់ភ្លន់ សន្តានចិត្តល្អ ការទទួលរាក់ទាក់ចំពោះអ្នកខាងក្រៅ ការអត់ធន់ និងគារវកិច្ចចំពោះអ្នកដទៃ នៅតែបដិបត្តិយ៉ាងម៉ឺងម៉ាត់។ និយាយតាមសេដ្ឋកិច្ចអាចមានការជយក្រោយ តែគុណភាពជីវិតប្រហែលជាខ្ពង់ខ្ពស់ជាង ប្រទេសសហរដ្ឋអាមេរិកជាដើម។

But even if we judge Buddhist countries in terms of economics alone, one of the wealthiest and most economically dynamic countries in the world today is Japan where 93% of the population call themselves Buddhist.

### *Why is it that you don't often hear of charitable work being done by Buddhists?*

Perhaps it is because Buddhists don't feel the need to boast about the good they do. Several years ago the Japanese Buddhist leader Nikkho Nirwano received the Templeton Prize for his work in promoting inter-religious harmony. Likewise a Thai Buddhist monk was recently awarded the prestigious Magsaysay Prize for his excellent work among drug addicts.

In 1987 another Thai monk, Ven.Kantayapiwat was awarded the Norwegian Children's Peace Prize for his many years work helping homeless children in rural areas. And what about the large scale social work being done among the poor in India by the Western Buddhist Order? They have built schools, child minding-centres, dispensaries and small scale industries for self-sufficiency. Buddhist see help given to others as an expression of their religious practice

តែទោះបីជាយ៉ាងណាក៏ដោយបើយើងកាត់សេចក្តីអោយបានច្បាស់ចំពោះ ប្រទេសដែលកាន់ ព្រះពុទ្ធសាសនាក្នុងរឿងសេដ្ឋកិច្ចតែម្យ៉ាង ប្រទេសមួយដែលមានអ ត្រាការធំធាត់ខាងសេដ្ឋកិច្ចនិងមានជាងគេបង្អស់ក្នុងពិភពលោកបច្ចុប្បន្ន គឺ ប្រទេសជប៉ុនដែល ប្រជាជន៩៣ភាព រយហៅខ្លួន ឯងថាជាពុទ្ធបរិស័ទ ។

### *បើដូច្នោះ ចុះហេតុអ្វីអ្នកមិនដែលឮជាញយៗទេអំពីការធ្វើបុណ្យរៃអង្គាសពីពុទ្ធសាសនិកជនទាំងឡាយ?*

ប្រហែលព្រោះថាពុទ្ធសាសនិកជនហាក់បីដូចមិនចង់លើកកំពស់អំពើល្អដែលគេធ្វើ ។ ច្រើនឆ្នាំកន្លងទៅហើយ មេដឹកនាំ ព្រះពុទ្ធសាសនាជនជាតិជប៉ុនឈ្មោះនិកកូ នារ៉ាណូ បានទទួលរង្វាន់ថឹមផ្លេតុនសំរាប់កិច្ចការលើកកំពស់សាមគ្គីធម៌ផ្ទៃក្នុងសាសនា ។ ដូចគ្នាដែរ ព្រះភិក្ខុសង្ឃថៃពេលថ្មីៗនេះបានទទួលរង្វាន់មែកសៃសៃដែលគួរអោយកោតសរសើរសំរាប់ការសំរេចដ៏ខ្ពង់ខ្ពស់នូវរឿងថ្នាំញៀនរបស់ ព្រះអង្គ ។

ក្នុងឆ្នាំ១៩៨៧ ភិក្ខុសង្ឃថៃមួយអង្គទៀតឈ្មោះ ព្រះតេជគុណខន្តិយពិវ៉ាត់ បានទទួលរង្វាន់សន្តិភាពរបស់ក្មេងរបស់ណ័រវេ សំរាប់ការងារច្រើនឆ្នាំរបស់ ព្រះអង្គក្នុងការជួយក្មេងអនាថាក្នុងតំបន់ដាច់ ស្រយាល ។ ហើយចុះអំពីគំរោងកិច្ចការសង្គមដ៏ធំក្នុងចំណោមជន ក្រី ក្រ ឥណ្ឌាដែលដំណើរការដោយ ក្រុមព្រះភិក្ខុសង្ឃមកពី ប្រទេសអ៊ឺរ៉ុប? ។ ពួកគេបានកសាងសាលារៀនមជ្ឈមណ្ឌលលើកកំពស់ស្មារតីក្មេង អាគារឱសថាល័យ និងរោងច ក្រ ឧស្សាហកម្មខ្នាតតូចសំរាប់លើកស្ទួយគុណភាពជីវិតខ្លួន ឯង ។ ពុទ្ធសាសនិកជនមើលឃើញការធ្វើទានដល់អ្នកដទៃជាការសំដែងកាបដិបត្តិខាងផ្លូវសាសនារបស់ពួកគេ

just as other religions do but they believe that it should be done quietly and without self-promotion. Thus you don't hear so much about their charitable work.

## *Why are there so many different types of Buddhism?*

There are many different types of sugar: brown sugar, white sugar, rock sugar, syrup and icing sugar but it is all sugar and it all tastes sweet. It is produced in different forms so that it can be used in different ways. Buddhism is the same: there is Theravada Buddhism, Zen Buddhism, Pure Land Buddhism, Yogacara Buddhism and Vajrayana Buddhism but it is all Buddhism and it all has the same taste - the taste of freedom.

Buddhism has evolved into different forms so that it can be relevant to the different cultures in which it exists. It has been reinterpreted over the centuries so that it can remain relevant to each new generation. Outwardly, the types of Buddhism may seem very different but at the centre of all of them is the Four Noble Truths and the Eightfold Path. All major religions, Buddhism included, have split into schools and sects. But the different sects of Buddhism have never gone to war with each other and to this day, they go to each other's temples and

ដូចគ្នានឹងការបដិបត្តិរបស់សាសនាដទៃ តែពួកគេគិតថាវាត្រូវតែធ្វើដោយសទ្ធាហើយមិនលើកតំកើងខ្លួនឯង ។ ដូច្នេះ អ្នកនឹងមិនឮច្រើនអំពីកិច្ចការធ្វើបុណ្យទានរបស់ពួកគេទេ ។

## *ហេតុអ្វីបានជាមានព្រះពុទ្ធសាសនាច្រើននិកាយប្លែកៗគ្នាច្រើនម្លេះ?*

មានស្ករប្រភេទផ្សេងៗជាច្រើន ដូចជាស្ករក្រហម ស្ករស ស្ករដុំ ស្ករទឹកស៊ីរ៉ូ និងស្ករលាបការ៉េម តែទាំងអស់នោះគឺជាស្ករហើយវាមានរសជាតិផ្អែមដូចគ្នា ។ វាត្រូវបានផលិតចេញពីទំរង់ផ្សេងៗគ្នា ដូច្នេះវាក៏អាចប្រើបានច្រើនយ៉ាងផ្សេងពីគ្នាដែរ ។ ព្រះពុទ្ធសាសនាក៏ដូចគ្នាដែរគឺមាននិកាយថេរវាទ និកាយហ្សេន និកាយសុខាវតី និកាយយោគះនិងនិកាយវជិរញ្ញាណ ។ តែនិកាយទាំងអស់នេះគឺព្រះពុទ្ធសាសនា ហើយមានរសជាតិតែមួយដូចគ្នាគឺរសជាតិនៃការអស់នូវសេចក្តីទុក្ខទាំងពួង ។

ព្រះពុទ្ធសាសនាបានវិវត្តន៍ជាទំរង់ផ្សេងៗគ្នា ដូច្នេះព្រះពុទ្ធសាសនាអាចសំរបជាមួយវប្បធម៌ផ្សេងៗគ្នាដែលមានរួចមកហើយ ។ ព្រះពុទ្ធសាសនាបានសំរបសំរួលសាចុះសាឡើងច្រើនសតវត្សន៍ដែលអាចរស់នៅសំរបជាមួយនឹងអនុជនជំនាន់ថ្មីជាបន្តបន្ទាប់ ។បើមើលពីខាងក្រៅឃើញថាព្រះពុទ្ធសាសនាមាននិកាយច្រើនដែលហាក់ដូចជាខុសគ្នាតែមជ្ឈន្តិកីនៃនិកាយទាំងអស់នោះគឺអរិយសច្ច៤និងអរិយមគ្គប្រកបដោយអង្គ៨ ។ សាសនាធំៗរួមទាំងព្រះពុទ្ធសាសនាបានបែកខ្ញែកជាក្រុមនិងនិកាយ ។ តែនិកាយផ្សេងៗគ្នារបស់ព្រះពុទ្ធសាសនាមិនដែលបង្កអោយមានសង្គ្រាមរវាងគ្នាឡើយហើយរហូតមកដល់បច្ចុប្បន្ននិកាយសាសនាទាំងអស់នោះនៅតែទៅមករកគ្នារវាងវត្តនិងវត្តនិងមានការ

worship together. Such tolerance and understanding is certainly rare.

### *Is Buddhism scientific?*

Before we answer that question it would be best to define the word 'science'. Science, according to the dictionary is: "knowledge which can be made into a system, which depends upon seeing and testing facts and stating general natural laws, a branch of such knowledge, anything that can be studied exactly". There are aspects of Buddhism that would not fit into this definition but the central teachings of Buddhism, the Four Noble Truths, most certainly would. Suffering, the First Noble Truth, is an experience that can be defined, experienced and measured. The Second Noble Truth states that suffering has a natural cause, craving, which likewise can be defined, experienced and measured. No attempted is made to explain suffering in terms of a metaphysical concept or myths. Suffering is ended, according to the Third Noble Truth, not by relying on upon a supreme being, by faith or by prayers but simply by removing its cause. This is axiomatic. The Fourth Noble Truth, the way to end suffering, once again, has nothing to do with metaphysics but depends on behaving in specific ways.

បដិបត្តិសាសនវិធីរួមគ្នា។ ខន្តិធម៌និងការយោគយល់គ្នាដូច្នេះគឺកម្រនឹងរកបានណាស់ ។

### *តើព្រះពុទ្ធសាសនាមានលក្ខណៈជាវិទ្យាសាស្ត្រទេ?*

មុននឹងឆ្លើយនូវសំណួរនេះវាជាការប្រសើរណាស់ដើម្បីកំណត់និយមន័យពាក្យវិទ្យាសាស្ត្រ។តាមវចនានុក្រម វិទ្យាសាស្ត្រមានន័យថា ចំណេះដឹងដែលអាចបង្កើតជាប្រព័ន្ធដែលអាស្រ័យកត្តាពិតដែលអាចពិសោធន៍ និងឃើញច្បាស់បាន ហើយថ្លែងទៅតាមច្បាប់ធម្មជាតិទូទៅ ជាសាខាចំណេះដឹងម្យ៉ាងដែលអាចសិក្សានូវសភាវពិតបាន។ មានទ្រឹស្តីខ្លះរបស់ព្រះពុទ្ធសាសនាដែលមិនសមស្របទៅតាមនិយមន័យនេះ តែពាក្យប្រៀនប្រដៅដែលសំខាន់បំផុតរបស់ព្រះពុទ្ធសាសនាគឺអរិយសច្ច៤ដែលមានលក្ខណៈជាវិទ្យាសាស្ត្រខ្លាំងបំផុត។ អរិយសច្ចៈទី១សេចក្តីទុក្ខគឺការពិសោធន៍ដែលយើងអាចកំណត់និយមន័យធ្វើការពិសោធន៍និងវាស់បាន។ អរិយសច្ចៈទី២ បង្ហាញថាសេចក្តីទុក្ខមានសាហេតុតាមធម្មជាតិគឺសេចក្តីចង់បានដែលជាហេតុអាចកំណត់និយមន័យ ធ្វើការពិសោធន៍និងវាស់ទំហំបាន។ គេមិនអាចបង្កើនការព្យាយាមពន្យល់សេចក្តីទុក្ខទៅនឹងគំនិតខាងបរមត្ថទស្សនវិជ្ជាឬទេវកថាទេ ។យោងតាមអរិយសច្ចៈទី៣សេចក្តីទុក្ខនឹងអាចបំបាត់បានដោយមិនអាស្រ័យទៅលើសភាវះអស្ចារ្យណាមួយ ដោយជំនឿ ឬដោយការអង្វរករបួងសួង តែសាមញ្ញបំផុតដោយការកំចាត់នូវសាហេតុរបស់វាចោល។ នេះគឺឃើញជាក់ច្បាស់ដោយខ្លួនឯង អរិយសច្ចទី៤គឺមាគ៌ាទៅរកការរំលត់នូវទុក្ខជាថ្មីម្តងទៀតជាគោលការណ៍ដែលមិនអាស្រ័យបរមត្ថទស្សនវិជ្ជាទាល់តែសោះ តែអាស្រ័យលើការបដិបត្តិត្រូវ

And once again behaviour is open to testing. Buddhism dispenses with the concept of a supreme being, as does science, and explains the origins and workings of the universe in terms of natural law. All of this certainly exhibits a scientific spirit. Once again, the Buddha's constant advice that we should not blindly believe but rather question, examine, inquire and rely on our own experience, has a definite scientific ring to it. He says:

*"Do not go by revelation or tradition, do not go by rumour, or the sacred scriptures, do not go by hearsay or mere logic, do not go by bias towards a notion or by another person's seeming ability and do not go by the idea 'He is our teacher'. But when you yourself know that a thing is good, that it is not blamable, that it is praised by the wise and when practised and observed that it leads to happiness, then follow that thing."*

So we could say that although Buddhism in not entirely scientific, it certainly has a strong overtone and is certainly more scientific than any other religion. It is significant that Albert Einstein, the greatest scientist of the twentieth century said of Buddhism:

*"The religion of the future will be a cosmic religion. It should transcend a personal God and avoid dogmas and theology. Covering both natural and spiritual, it should be based on a religious sense arising from the experience of all things, natural and spiritual and a meaningful unity. Buddhism answers this description. If there is any religion that would cope with modern scientific needs, it would be Buddhism."*

ហើយបើកទូលាយសំរាប់អ្នកបដិបត្តិពិសោធន៍មើលម្តងហើយម្តងទៀត។ ព្រះពុទ្ធសាសនាមិនទទួលស្គាល់នូវគំនិតជឿលើសភាវៈអស្ចារ្យដូចគ្នានឹងវិទ្យាសាស្ត្រដែរ ហើយពន្យល់នូវសាហេតុនិងកិច្ចការរបស់ចក្រវាឡដោយសំអាងលើច្បាប់ធម្មជាតិ។ ទាំងអស់នេះឈរនៅលើការបង្ហាញនូវចិត្តវិញ្ញាណនៃវិទ្យាសាស្ត្រ។ បន្ថែមលើនេះទៀតពាក្យទូន្មានជាញឹកញាប់របស់ព្រះពុទ្ធ គឺមិនអោយយើងជឿទាំងងងឹតងងល់ តែគួរចោទសួរខ្លះ ត្រួតពិនិត្យ ស៊ើបអង្កេត និងសំអាងលើការពិសោធន៍ដោយខ្លួនឯង ដោយមានបន្លឺរោទ៍ទ្រឹស្តីវិទ្យាសាស្ត្រនិយាយថា *'ចូរកុំបណ្តោយខ្លួនជឿទៅតាមការប្រកាសដំណឹងល្អឬទំនៀមទំលាប់,ចូរកុំបណ្តោយខ្លួនជឿទៅតាមពាក្យចចាមអារាម ឬគម្ពីរសក្តិសិទ្ធិ កុំបណ្តោយខ្លួនជឿទៅតាមពាក្យបំផ្លើសឬគ្រាន់តែតក្កៈកុំបណ្តោយខ្លួនជឿទៅតាមភាពអគតិតាមការសង្កេតឬដោយសមត្ថភាពដែលសំដែងចេញរបស់មនុស្ស និងកុំបណ្តោយខ្លួនជឿទៅតាមគំនិតថាគាត់ជាគ្រូរបស់យើង។ តែបើនៅពេលខ្លួនអ្នក ផ្ទាល់ដឹងថាវត្ថុនេះល្អដែលមិនអាចបន្ទោសបាន ដែលលើកសរសើរដោយបណ្ឌិតហើយពេលបានបដិបត្តិនិងសង្កេត ឃើញថាវានាំទៅរកសេចក្តីសុខ ដូច្នេះចូរបណ្តោយខ្លួនជឿតាមវត្ថុនោះ*។ ដូច្នេះយើងអាចនិយាយថា ថ្វីបើព្រះពុទ្ធសាសនាមិនមែនជាវិទ្យាសាស្ត្រទាំងស្រុង តែតាមសេចក្តីពិតគឺមានសំលេងជាវិទ្យាសាស្ត្រខ្លាំង ហើយមានលក្ខណៈជាវិទ្យាសាស្ត្រជាងសាសនាដទៃ។វាជាការឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាលោកអាលបើត អែស្តាញ ជាអ្នកវិទ្យាសាស្ត្រដ៏ល្បីល្បាញម្នាក់ក្នុងសតវត្សន៍ទី២០និយាយអំពីព្រះពុទ្ធសាសនាថា *"សាសនានៃអនាគតគឺជាសាសនាសាកល។ អាចពុះពារជំនះលើវត្ថុមានអាទិទេព្យនិងជៀសផុតពីគំនិតទិដ្ឋិនិយមនិងទេវវិទ្យា។ គ្របដណ្តប់ទាំងសភាវៈធម្មជាតិ និងចិត្តវិញ្ញាណវាអាចមានគោលជំហរលើសម្បជញ្ញៈខាងសាសនាដែលផុសឡើងពីបទពិសោធន៍លើវត្ថុទាំងអស់ទាំងធម្មជាតិ និងចិត្តវិញ្ញាណនិងកត្តារួមដ៏ជាក់លាក់។បើមានសាសនាណាមួយអាចគ្រប់គ្រងលើតំរូវការរបស់វិទ្យាសាស្ត្រសម័យទំនើបថ្មីនោះបាន គឺព្រះពុទ្ធសាសនា"* ។